# សុន្ទរកថារបស់ លោក វ៉ាដា តាកាយូត
# លេខាទីពីរ ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ
# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធអគារសិក្សានៃគម្រោងសាងសង់ និងជួសជុលអនុវិទ្យាល័យ
# និងសាលាបឋមសិក្សានៅខេត្តកំពត
# ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤

សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!
សូមគោរព **ឯកឧត្តម ខូយ ឃុនហួរ** អភិបាលខេត្តកំពត!
សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់!

ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានមកចូលរួមក្នុងពិធីសម្ពោធអគារសិក្សានៃគម្រោងសាងសង់ និងជួសជុលអនុវិទ្យាល័យ និងសាលាបឋមសិក្សានៅខេត្តកំពត នៅថ្ងៃនេះជាមួយនឹងវត្តមានរបស់ **ឯកឧត្តម ខូយ ឃុនហួរ** អភិបាលខេត្តកំពត។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងអប់រំ យុវជន និងកីឡា និងជាពិសេស សមាគមជំនួយសាលារៀននៅកម្ពុជា (ASAC) ដែលបានសម្របសម្រួល និងអនុវត្តគម្រោងនេះ។

ការធានានូវការទទួលបានការអប់រំកម្រិតបឋមសិក្សា គឺជាគោលដៅចម្បងមួយនាពេលបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជា។ ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែលម្អវិស័យអប់រំ។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំជាមូល ដ្ឋានដើម្បីសម្រេចបាននូវការអភិវឌ្ឍធនធានមនុស្សនោះ រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ជំនួយឧបត្ថម្ភរបស់ខ្លួនដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាតាមរយៈការជួយសាងសង់សាលារៀន ក៏ដូចជាបណ្តុះបណ្តាលគ្រូបង្រៀនជាដើមតាំងពីឆ្នាំ១៩៩០មកម្ល៉េះ។

តាមដែលខ្ញុំបានដឹងមានសិស្សានុសិស្សប្រមាណ ៦០០នាក់ ត្រូវសិក្សានៅក្នុងថ្នាក់រៀនដែលគ្មានសុវត្ថិភាព ដោយសារមិនមានអគារសិក្សាគ្រប់គ្រាន់។ ចាប់ពីបវេសនកាលនេះទៅ សិស្សានុសិស្សបឋមសិក្សាប្រមាណ៤០០នាក់នឹងចាប់ផ្តើមរៀនសូត្រនៅក្នុងអគារសិក្សាដែលទើបជួសជុលរួច ហើយសិស្សានុសិស្សអនុវិទ្យាល័យប្រមាណ៣០០នាក់ នឹងចាប់ផ្តើមរៀនសូត្រនៅក្នុងអគារសិក្សា២ខ្នងមាន៨បន្ទប់ទើបសាងសង់ថ្មី រួមនិងបន្ទប់អនាម័យ ៤បន្ទប់ ផង។ ក្រៅពីនេះ មានអគារបណ្ណាល័យមួយខ្នងដែលនឹងបើកទទួលមិនថាតែសិក្សានុសិស្សនោះទេ ប៉ុន្តែសម្រាប់ប្រជាពលរដ្ឋដែលរស់នៅភូមិកំណប់នេះផងដែរ។ គម្រោងនេះនឹងអនុញ្ញាតិឲ្យក្មួយៗសិស្សានុសិស្សទាំងនៅកម្រិតបឋមសិក្សា និងអនុវិទ្យាល័យទទួលបាននូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងជាសុខភាព ក៏ដូចជាឱកាសក្នុងការអានផងដែរ។

នៅកំឡុងពេលទស្សនកិច្ចលើកដំបូង របស់ខ្ញុំមកកាន់ភូមិនេះ ដើម្បីសិក្សាពីស្ថានភាពទូទៅនៅដំណាក់កាលដំបូង ដូចជាមិនទាន់ឃើញមានខ្សែភ្លើងនិងហាងលក់ដូរនៅឡើយទេ ជាងនេះទៅទៀតនោះ កុមារជាច្រើនមិនមានបន្ទប់រៀនគ្រប់គ្រាន់សម្រាប់សិក្សារៀនសូត្រនៅឡើយទេ។ រហូតដល់ទស្សនកិច្ច លើកចុងក្រោយរបស់ខ្ញុំដើម្បីពិនិត្យមើលការអនុវត្តគម្រោងនោះ នៅក្នុងភូមិនេះបានទទួលការតភ្ជាប់បណ្តាញអគ្គិសនីរួចហើយ ហើយក៏មានអាជីវកម្មមួយចំនួនបានចាប់ផ្តើមបើកដែរ។ នៅថ្ងៃនេះសាលារៀនថ្មីនឹងត្រូវបើកសម្ពោធក្រោមការស្វាគមន៍ដ៏កក់ក្តៅពីសំណាក់ប្រជាពលរដ្ឋដ៏ច្រើនកុះករ។ ខ្ញុំមានសេចក្តីរីករាយដែលបានឃើញការរីកចម្រើនដ៏ឆាប់រហ័សរបស់ភូមិស្រុកនេះ តែក្នុងរយៈពេលមួយឆ្នាំប៉ុណ្ណោះនៃដំណើរទស្សនកិច្ចរបស់ខ្ញុំ ហើយខ្ញុំសង្ឃឹមថាការអភិវឌ្ឍនេះនឹងធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃការរស់នៅរបស់ប្រជាជន។

ខ្ញុំសង្ឃឹមថាក្មួយៗសិស្សានុសិស្សនៅទួលធ្នឹកទាំងអស់ នឹងអាចបញ្ចប់ការសិក្សារបស់ក្មួយៗនៅក្នុងថ្នាក់រៀនដែលមានបរិស្ថានសិក្សាល្អប្រសើរនេះ ដូចនេះសូមជួយថែរក្សាអគារនេះឲ្យបាននៅគង់វង្សល្អ ទុកជានិមិត្តរូបដ៏យូរអង្វែងមួយនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យគម្រោងនេះដំណើរការទៅបានដោយរលូន។ ខ្ញុំស ង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះនឹងជួយ ពង្រឹងជាបន្តទៅទៀត នូវទំនាក់ទំនងមិត្តភា ពរវាង ប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!